# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៧)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jul-2021, 09:48
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គបុរេជំនុំជម្រះ** ៖

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៧)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) តាមរយៈនេះ ឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ.”) សុំឱ្យបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣[1]។ ស.ព.អ. ស្នើសុំដំណោះស្រាយ ដែលមិនអាចទទួលយកបាន។ អង្គបុរេជំនុំជម្រះ (“អ.ប.ជ.”) មិនបានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ទោះយ៉ាងណាក្តី ក៏ចេតនារបស់ចៅក្រមជាតិនៃ អ.ប.ជ. មិនមានភាពច្បាស់លាស់ឡើយ។ ប៉ុន្តែបើទោះបីជាចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយសហចៅក្រមស៊ើបអង្កេត (“ស.ច.ស.”) ម្នាក់ក្តី តែក៏មិនមែនមានន័យថា ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស. ម្នាក់ទៀត គ្មានទម្ងន់ឡើយ។ ដីកាដំណោះស្រាយទាំងពីរ គឺមានទម្ងន់ស្មើគ្នា ដែលធ្វើឱ្យប៉ះពាល់ដល់និច្ចលភាព។ ការមិនព្រមព្រៀងគ្នា ដោយសំឡេងភាគច្រើនលើសលុបក្នុងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅអង្គជំនុំជម្រះសាលាដំបូង (“អ.ជ.ស.ដ.”) ដែលហាក់ដូចជាស្ថានភាពនាពេលបច្ចុប្បន្ននេះ តម្រូវឱ្យ អ.ប.ជ. បញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ ដើម្បីជៀសវាងពីការរំលោភនីតិវិធី ដែលនឹងតម្រូវដោយមិនអាចជៀសបាន នូវការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក.”) ឬ ស.ច.ស.។ មេធាវីការពារក្តីស្នើសុំដាក់ចម្លើយនេះជាភាសាអង់គ្លេសជាមុនសិន ដោយដាក់ការបកប្រែជាភាសាខ្មែរជូនតាមក្រោយ ពីព្រោះថាអង្គភាពបកប្រែភាសាមិនអាចបញ្ចប់ការបកប្រែក្នុងរយៈពេលកំណត់ដោយ អ.ប.ជ. បានឡើយ[2]។

## I. សាវតារ

១. ក្រោយទទួលពិនិត្យដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា អ.ប.ជ. ខកខានមិនបានឈោងដល់សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុបលើបញ្ហាថា តើរឿងក្តី ០០៣ គួរបញ្ជូនទៅជំនុំជម្រះដែរ

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D271/1 (“សំណើរបស់ ស.ព.អ.”)។

[2] សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី “កម្មវត្ថុ៖ សំណើសុំបកប្រែ” ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០២១ សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះជូនភាគីនៅក្នុងសំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៧) ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០២១។

ឬទេ[3] បើទោះបីជាចំណាយពេលដល់ទៅ ១៦ ខែ ដើម្បីពិភាក្សាសម្រេច[4] និង មានការប្រមើលមើលរយៈពេលប្រាំបីខែ អំពីអន្តរាគមន៍របស់ អ.ជ.ត.ក. ក្នុងការបញ្ចប់ភាពជាប់គាំងរបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២[5]។ ខណៈដែល អ.ប.ជ. បានយល់ស្របគ្នាដោយផ្នែកក្តី តែចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានចេញនូវមតិដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា ដោយស្នើសុំឱ្យដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ និង ឱ្យបញ្ជូនទៅជំនុំជម្រះ[6]។ ចៅក្រមជាតិនៃ អ.ប.ជ ជាជាងតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ និង សម្រេចថាដីកាបញ្ជូនរឿងទៅជំនុំជម្រះអសុពល តាមវិធាន ៧៧(១៣) ដូចដែលខ្លួនបានសម្រេចក្នុងរឿងក្តី ០០៤/២[7] បែរជាយល់ឃើញថា ន័យដូចចែងក្នុងវិធាន ៧៧(១៣) "ដីកាដំណោះស្រាយទាំងពីរ មានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា"[8]។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានអនុម័តយកវិធីសាស្ត្រនៃរឿងក្តី ០០៤/២ សម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង យល់ឃើញថាដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវទុកជាមោឃៈ និង ឥតបានការ[9]។

២. ការអះអាងថា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស.ព.អ. បានស្នើសុំ ស.ច.ស. ឱ្យចាត់វាល់វិធានការរដ្ឋបាលចាំបាច់នានា ដើម្បីបញ្ជូនសំណុំរឿង ០០៣ ទៅ

---

[3] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 & D267/35 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣") កថាខណ្ឌ ១១០ ទំព័រ ៥៥។

[4] ទឡ្ហីករណ៍ផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងជា*អសាធារណៈ* នៅថ្ងៃទី ២៧-២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៩ ឯកសារ D266/12។

[5] *រឿងក្តី* អោ អាន សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២")។

[6] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ទំព័រ ៥៦, កថាខណ្ឌ ១១១-១១៨, ទំព័រ ៥៩ , កថាខណ្ឌ ១១៩-៣៥៨, ទំព័រ ២០៧។

[7] *រឿងក្តី* អោ អាន សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អ.ប.ជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 & D360/33 ("សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៤/២") កថាខណ្ឌ ៣០២។

[8] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៥។

[9] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៦០, ២៦២។

អ.ជ.ស.ដ.[10]។ ស.ច.ស. បានច្រានចោលសំណើរបស់គាត់ ដោយសារមិនមានមូលដ្ឋានសមស្រប ដោយសម្រេចថា ការសំអាងដែលថា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "គឺធ្វើឱ្យពាក្យពេចន៍របស់ចៅក្រមជាតិ ស្ថិតក្រៅបរិបទ ទាំងនៅក្នុងសេចក្តីពិចារណាក្នុងរឿងក្តី ០០៣ ផ្ទាល់ និង ទាំងប្រៀបធៀបជាមួយសេចក្តីពិចារណាក្នុងរឿងក្តី ០០៤/២ ដែលត្រូវបានចេញសឹងតែ*ភ្លាមៗ* បន្ទាប់ពីសវនាការក្នុងរឿងក្តី ០០៣"[11]។ ដោយយល់ឃើញថា ខ្លួនមិនមានយុត្តាធិការ ដោយសារតែរឿងក្តីស្ថិតនៅក្នុងដៃរបស់ អ.ប.ជ. នោះ ស.ច.ស. បានផ្តល់ដល់ អ.ប.ជ. នូវដំណោះស្រាយចំនួនបី ដើម្បីបំបែកភាពជាប់គាំង (ដោយមិនយកចិត្តទុកដាក់នូវដំណោះស្រាយដែលផ្តល់ដល់ អ.ប.ជ. ដោយសារណានាពេលកន្លងមករបស់មេធាវីការពារក្តី)[12]៖ (ក) បង្វិលត្រឡប់សំណុំរឿង ដោយមានសេចក្តីណែនាំ (ខ) "បំពេញកិច្ចដោយខ្លួនឯងផ្ទាល់ជាឯកច្ឆន្ទ ដោយអនុវត្តវិធានរកសំឡេងមិនបាន ហើយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ" ឬ (គ) "បញ្ចប់សំណុំរឿង ដូចដែល អ.ជ.ត.ក. បានសម្រេចផ្តាច់ព្រាត់ក្នុងសំណុំរឿង ០០៤/២"[13]។

៣. មេធាវីការពារក្តីស្នើសុំ អ.ប.ជ. ឱ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ ដោយពិចារណាពីសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការសន្និដ្ឋានបញ្ចប់ដំណើរការនីតិវិធីប្រឆាំងរូបគាត់ ក្នុងពេលវេលាសមស្របមួយ ការពន្យារពេលដោយមិនសមហេតុផលក្នុងដំណើរការនីតិវិធីមុនពេលជំនុំជម្រះដែលមានរយៈពេល ១៣ ឆ្នាំ និង ការពិតដែលថា ដំណើរការនីតិវិធីជំនុំជម្រះ និង ដំណើរការនៃបណ្តឹងសាទុក្ខ នឹងត្រូវចំណាយពេលយ៉ាងហោចណាស់ បួនឆ្នាំ

---

[10] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ឯកសារ D270។

[11] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣") កថាខណ្ឌ ៣០ (ការគូសបញ្ជាក់ក្នុងឯកសារដើម)។

[12] ប្រតិចារឹកសវនាការបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០២១ ឯកសារ D266/18.2 ម៉ោង 11.58.39-12.04.14។ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២០ ឯកសារ D267/24 កថាខណ្ឌ ១, ១៥, ២៣, ៣១, ៣៣។ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 ("សារណាបន្ថែមរបស់ មាស មុត") កថាខណ្ឌ ២៥-៤៩។

[13] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៥, ៤០។

បន្ថែមទៀត ដែលទាំងអស់នេះរួមជាមួយការជាប់គាំងដែលកំពុងបន្តដោយមិនអាចកំណត់បាន ក្នុងចំណោមក្រុមទាំងពីររបស់ អ.ប.ជ. នោះ គឺបង្កើតបានជាការរំលោភនីតិវិធី ដែលនៅតែបន្តមាន និង មិនអាចកែប្រែបាន[14]។ ផ្ទុយទៅវិញ ស.ព.អ. ស្នើសុំ អ.ប.ជ. ឱ្យបញ្ចប់ដំណើរការនីតិវិធីមុនការជំនុំជម្រះ ដោយបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ អនុលោមតាមការយល់ឃើញ "ជាឯកច្ឆន្ទ" របស់ អ.ប.ជ. ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[15] ម្យ៉ាងវិញទៀត ដោយអះអាងថា បើទោះ អ.ប.ជ. មិនអើពើនឹងការយល់ឃើញរបស់ខ្លួនក្តី ក៏ក្របខណ្ឌ អ.វ.ត.ក. តម្រូវថា រឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ[16]។ រវាងដំណោះស្រាយផ្ទុយគ្នាទាំងស្រុងដែលបានស្នើដោយមេធាវីការពារក្តី និង ស.ព.អ. អ.ប.ជ. បានទុកចោល ដោយមិនពិចារណារកផ្លូវកណ្តាលណាមួយ ឬ រកការសម្របសម្រួលផ្លូវច្បាប់ ដែលជំនួសឱ្យសេចក្តីសម្រេចបញ្ចប់ទេ។

## II. ភាពអាចទទួលយកបាន

៤. រឿងក្តី ០០៣ កំពុងស្ថិតក្នុងការជាប់គាំងផ្នែកតុលាការ។ ស.ព.អ. បានកត់សម្គាល់ដោយត្រឹមត្រូវថា ការខកខានរបស់ អ.ប.ជ. មិនបានសម្រេចដោយច្បាស់លាស់ នូវជោគវាសនានៃរឿងក្តី ០០៣ ថា ត្រូវបញ្ជូនទៅជំនុំជម្រះ ឬ ដាក់បញ្ចូលទៅក្នុងបណ្ណសារ ដោយបង្វែរទំនួលខុសត្រូវទៅផ្នែកផ្សេងទៀតនៃ អ.វ.ត.ក. "ក្នុងការបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃដំណើរការនីតិវិធី ដើម្បីរារាំងអពលានុភាពផ្នែកស្ថាប័នដែលបានដាក់តាមផ្លូវតុលាការ"[17]។ ប្រសិនអ្វីៗកន្លងមកជាបុរេកថា នោះការបញ្ចប់គឺជាសេចក្តីសន្និដ្ឋានដែលត្រូវធ្វើ ប្រសិនបើ អ.ប.ជ. ខកខានមិនបានបំពេញកិច្ចនោះការច្រានចោលរបស់ អ.ជ.ស.ដ. លើសំណើរបស់ ស.ព.អ. សុំបន្ថែមបញ្ជីឈ្មោះសាក្សីរបស់ខ្លួន[18] "ជាចុងក្រោយនឹងបើកផ្លូវដល់ការសម្រេចមួយផ្សេងទៀតរបស់ អ.ជ.ត.ក. ដូចនៅក្នុង

---

[14] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D272 ("សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ") កថាខណ្ឌ ៤៧-៧៣។

[15] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១១ -២១។

[16] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២២ -៣៣។

[17] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៤។

[18] សារអេឡិចត្រូនិកពី លឹម សុយហ៊ុង ចំណងជើង "កម្មវត្ថុ៖ សំណើសុំពន្យារពេលដាក់បញ្ជីសាក្សី និង អ្នកជំនាញ តាមវិធាន ៨០ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២១។

រឿងក្តី ០០៤/២”[19]។ បន្ថែមលើនេះ ទោះបីជា ស.ច.ស. “មិនមានយុត្តាធិការក្នុងការសម្រេចលើ ជោគវាសនារឿងក្តី ០០៣ ដោយសារតែរឿងក្តីនេះស្ថិតក្នុងការរង់ចាំការសម្រេចរបស់ អ.ប.ជ.”ក៏ដោយ ជាការសមស្រប ពួកគេក៏បានបង្ហាញពីចេតនារបស់ខ្លួន ដើម្បីសម្រេចកាត់យ៉ាងដាច់ខាតនូវចំណោទដ៏ស្មុគស្មាញថា ៖

> ជាជម្រើសចុងក្រោយបំផុត និង បន្ទាប់ពីដំណើរការអស់នូវយុត្តាធិការទាំងឡាយដែលមានពួកយើងនឹងបើកឱកាសទទួលយក ឬ ស្នើសុំនូវទឡ្ហីករណ៍នានាអំពីបញ្ហាថា តើពួកយើងមានយុត្តាធិការដែលនៅសេសសល់ពិសេសណាមួយ ដែលជាមធ្យោបាយចុងក្រោយបំផុតក្នុងការបញ្ចប់សំណុំរឿងដោយខ្លួនឯង ដើម្បីផ្តល់ប្រសិទ្ធិភាពដល់គោលការណ៍ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលមានកម្រិតខ្ពស់ជាង ក្នុងការសម្រេចសេចក្តីទៅលើសំណុំរឿងឱ្យបានត្រឹមត្រូវ និង ដើម្បីការពារសិទ្ធិរបស់ មាស មុត ក្នុងការទទួលបាននូវការសម្រេចជាស្ថាពរទៅលើសំណុំរឿងប្រឆាំងនឹងខ្លួនឱ្យបានឆាប់រហ័ស[20]។

៥. នៅក្នុងបរិបទនេះ ជាក់ស្តែង ស.ព.អ. បានលើកឡើងយ៉ាងសមស្របនូវបញ្ហាគ្របដណ្តប់រួមចំនួនពីរ ដែលតម្រូវឱ្យមានដំណោះស្រាយពី អ.ប.ជ.។ ជាពិសេស ការទទួលពិនិត្យរឿងក្តី ០០៣ អ.ប.ជ. ចាំបាច់ត្រូវបញ្ឈប់ការម្រេចបិទបាំងដោយភ័យខ្លាច និង ដាច់ណាត់ ហេតុនេះហើយ ជាហេតុដែលមេធាវីការពារក្តីពុំបានជំទាស់នឹងការទទួលយកសំណើរបស់ ស.ព.អ. ទោះបីជាវាជាផ្លូវការមិនអាចទទួលយកបានក្តី[21] និង ទោះបីជាកាលៈទេសៈស្រដៀងគ្នាទាំងអស់នេះ*បានឃើញរួចហើយ* ត្រូវបានច្រានចោលភ្លាមៗក្តី។

---

[19] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៤០។

[20] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៤២។

[21] ស.ព.អ. មានសិទ្ធិតាមវិធាន៧៤(២) ក្នុងការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេច និង ដីកាទាំងអស់របស់ ស.ច.ស. ហើយត្រូវបាន ស.ច.ស. លើកទឹកចិត្តយ៉ាងច្បាស់លាស់ ឱ្យប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅ អ.ជ.ស.ជ.។ ស.ព.អ. សម្រេចមិនប្តឹង ជំនួសការជូនដំណឹងទៅ អ.ប.ជ. ភាគីនានា និង សាធារណជន អំពីចេតនារបស់ខ្លួន ក្នុងការដាក់សំណើនេះទៅវិញ។ *សូមមើល* សេចក្តីសម្រេចរបស់ ស.ច.ស. សុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៤៣។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីបំណងរបស់ខ្លួន ក្នុងការដាក់សំណើសុំឱ្យអង្គបុរេជំនុំជម្រះ បិទបញ្ចប់ដំណាក់កាលមុនជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D271។

## III. បញ្ហាគ្របដណ្ដប់រួម និង ចម្លើយខ្លីៗ

**បញ្ហា** *ថាតើចៅក្រមជាតិនៃ អ.ប.ជ. បានប៉ុនប៉ងសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ក៏ចូលរួមជាមួយសហការីរបស់ខ្លួន ជាចៅក្រមអន្តរជាតិ នៅទិដ្ឋភាពដទៃទៀតនៃសេចក្តីពិចារណា "ជាឯកច្ឆន្ទ"ដែរឬទេ នៅពេលដែលពួកគាត់បានសន្និដ្ឋាន នៅក្នុងមតិផ្សេងរបស់ពួកគាត់ ដែលថារឿងក្តី ០០៣ គួរដាក់បញ្ចូលទៅក្នុងបណ្ណាសា។*

**ចម្លើយ** ទេ។ វាអាចមានការដេញដោលគ្នាដែលថា តើ អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬទេ។ នៅពេលពិចារណាមតិផ្សេងរបស់ពួកគាត់ រួមជាមួយសេចក្តីពិចារណា"ជាឯកច្ឆន្ទ" វាមានភាពមិនច្បាស់លាស់ថា តើចៅក្រមជាតិនៃ អ.ប.ជ. បានយល់ដឹងទាំងស្រុង និង បានស្វែងយល់ខ្លឹមសារ និង បរិបទពេញលេញនៃការយល់ឃើញ "ជាឯកច្ឆន្ទ" ដែរឬទេ។ ចាំបាច់ត្រូវមានការបញ្ជាក់បំភ្លឺ ដែលមានតែចៅក្រមជាតិនៃ អ.ប.ជ. ប៉ុណ្ណោះ ដែលអាច និង ដែលត្រូវតែកំណត់។

**បញ្ហា** *តើក្របខណ្ឌ អ.វ.ត.ក. តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានឧត្តមភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ និង ត្រូវបញ្ជូនទៅ អ.ជ.ស.ដ. ដែរឬទេ ប្រសិនបើវាមិនត្រូវបានច្រានចោល ដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ.។*

**ចម្លើយ** ទេ។ បើទោះបីជា អ.ប.ជ. ពិតជាបានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី ក៏តាមក្របខណ្ឌ អ.វ.ត.ក. ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស. មួយនាក់ មិនអាចមានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស. មួយនាក់ផ្សេងទៀតឡើយ។ ដីកាដំណោះស្រាយទាំងពីរ នឹងនៅតាមលងបន្លាចជារឿងរហូត វៀរលែងតែ អ.ប.ជ. ឬ អង្គជំនុំជម្រះដទៃទៀតរបស់ អ.វ.ត.ក. ប្រើប្រាស់សិទ្ធិអំណាច និង ទំនួលខុសត្រូវរបស់ខ្លួន ក្នុងការបញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ។

## IV. ចម្លើយ

### ក. វាអាចមានការពិភាក្សាដេញដោលគ្នាដែលថា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៦. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា អ.ប.ជ. ត្រូវតែបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ បន្ទាប់ពីការយល់ឃើញ"ជាឯកច្ឆន្ទ"ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[22]។ នៅពេលពិចារណាមតិផ្សេងគ្នារបស់ពួកគេ រួមជាមួយសេចក្តីពិចារណា"ជាឯកច្ឆន្ទ" វាមិនមានភាពច្បាស់លាស់ឡើយថា តើចៅក្រមជាតិនៃ អ.ប.ជ. បានយល់ដឹង និង អបអរទាំងស្រុងចំពោះខ្លឹមសារ និងបរិបទទាំងមូលនៃការយល់ឃើញ"ជាឯកច្ឆន្ទ" ដែរឬទេ ជាពិសេស នៅពេលដែលវិជ្ជាជីវៈ និងសុចរិតភាពរបស់ ស.ច.ស. រងការទិតៀនដោយមិនសមហេតុផល និង មិនចាំបាច់។ ជាក់ស្តែង មតិផ្សេងគ្នារបស់ពួកគាត់ គឺមិនអាចផ្សះផ្សាបាន ជាមួយសេចក្តីពិចារណា"ជាឯកច្ឆន្ទ" ទាំងទៅលើបញ្ហាស្នូល និង បញ្ហាបេ្តជ្ញា ដូចជាថាតើ ៖ (ក) ត្រូវអនុវត្តគោលជំហរដើមឬទេ (ខ) ត្រូវអនុវត្តវិធាន ៧៧(១៣)ឬទេ (គ) ត្រូវអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ឬទេ និង ជាចុងក្រោយ (ឃ) អ.វ.ត.ក. មានយុត្តាធិការបុគ្គលទៅលើលោក មាស មុត ឬទេ។ វាមិនសមតាមតក្កវិជ្ជាឡើយ ដែលភ្លីភ្លើមិនអើពើនឹងភាពមិនស្របគ្នាទាំងនេះ ហើយធ្វើពុតធ្វើពើផ្សេងទៅវិញ ជាជាងឱ្យចៅក្រមជាតិនៃ អ.ប.ជ. ធ្វើការបំភ្លឺ ដែលមានតែពួកគាត់ប៉ុណ្ណោះដែល *អាច* និង ដែល *ត្រូវតែ* ធ្វើ។

៧. ***ចៅក្រមជាតិនៃ អ.ប.ជ.ហាក់ដូចជាយល់ស្របថា គោលជំហរដើម មិនអាចអនុវត្តបានទេ។*** អ.ប.ជ. មិនសមជាអង្គការតុលាការនៃសាលាក្តីកម្រិតអន្តរជាតិ ហែលជ្រកក្រោមបដានៃអង្គការសហប្រជាជាតិ បែរជាបានចោទប្រកាន់ ស.ច.ស. ដោយឯកច្ឆន្ទ អំពី "*ការអនុវត្តដោយខុសឆ្គង*" ក្នុងការនាំដំណើរការយុត្តិធម៌ទៅផ្លូវអាក្រក់ដោយចេតនា និង ដោយមានការគិតគូរ តាមការ "សម្រេចដោយចេតនាក្នុងការគេចវេស" ពីយន្តការដោះស្រាយជម្លោះ[23] "ដើម្បីធ្វើឱ្យបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិអំណាចរបស់ អ.ប.ជ."[24]។ ដោយសារតែ ស.ច.ស. មិនអាច

---

[22] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១២ -២១។

[23] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៩០។

[24] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

យល់ស្របគ្នា លើដំណើរការសកម្មភាព ដែលជាប់ទាក់ទងនឹងគោលជំហរដើម (ដែលអ៊ីចឹងហើយបានជារឿងក្ដីតែងតែបន្ដដំណើរ" ទើប អ.ប.ជ. បានយល់ឃើញថា ស.ច.ស. ត្រូវបានតម្រូវឱ្យប្ដឹងទៅ អ.ប.ជ. តាមយន្ដការដោះស្រាយជម្លោះតាមវិធាន ៧២[25]។ ការ"ថ្កោលទោសសារជាថ្មីម្ដងទៀត ទៅលើស្ថានភាពដ៏អាក្រក់ផ្នែកផ្លូវច្បាប់ ដែលសកម្មភាពខុសច្បាប់របស់ ស.ច.ស. បានបង្កើតឡើង ចំពោះដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក."[26] ទើប អ.ប.ជ. បានយល់ឃើញថា តាមការរារាំងដោយឥតគិតក្រែង មិនអនុវត្តភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការប្រកាសទៅលើបញ្ហា[27] នោះ ស.ច.ស. "បានបង្កអន្ដរាយដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ"[28] និង "ធ្វើឱ្យមូលដ្ឋាននៃប្រព័ន្ធចម្រុះ និង ដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក. រងក្ដីវិនាស"[29]។

៨. ផ្ទុយទៅវិញ និង ដោយមិនមានការប្រើប្រាស់ពាក្យពេចន៍ធ្ងន់ធ្ងរ ដែលប្រើនៅក្នុងសេចក្ដីពិចារណា "ជាឯកច្ឆន្ទ" ក្នុងការបន្ទុះបង្អាប់វិជ្ជាជីវៈ និង សុចរិតភាពរបស់ ស.ច.ស. (ហើយច្រើនស្របគ្នានឹងការគោរព និង កិត្តិយស ដែលមានចែងនៅក្នុងក្រមសីលធម៌តុលាការរបស់កម្ពុជា[30] និង វប្បធម៌កម្ពុជា) ចៅក្រមជាតិនៃ អ.ប.ជ. នៅក្នុងមតិដាច់ដោយឡែករបស់ខ្លួន បានពិចារណាឃើញថា៖ (ក) ស.ច.ស. ទាំងពីរ បានយល់ព្រមរក្សាការខ្វែងយោបល់គ្នានៅក្នុងការិយាល័យរបស់ខ្លួន ដោយមិនប្ដឹងទៅ អ.ប.ជ. ស្របតាមវិធាន ៧២ (ខ) "អ.ប.ជ. ពុំអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងវិធាន ៧២ ឡើយ" និង (គ) តាមវិធាន ៧៧(១៣) ថា ដីកាដំណោះស្រាយទាំងពីរ "មានតម្លៃដូចគ្នា និង មានសុពលភាពជាធរមាន"[31]។

---

[25] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៩៤, ១០០។ *សូមមើលផងដែរ* សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២២។

[26] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៩។

[27] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៥។

[28] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៨។

[29] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៦។

[30] សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ១១ ដែលដកស្រង់មាត្រា ១, ១៥, ២៤ នៃក្រមសីលធម៌តុលាការកម្ពុជា។ *សូមមើលផងដែរ* មាត្រា ៣(១), ៦(១), ៦(៣), ៧(២) នៃក្រមសីលធម៌តុលាការ អ.វ.ត.ក។

[31] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៣, ១១៥។

៩. ទាក់ទិននឹងបញ្ហាថា តើសេចក្ដីពិចារណា"ជាឯកច្ឆន្ទ" តាមពិត "ត្រូវបានព្រាងជាឯកច្ឆន្ទ"[32]ឬទេនោះ ជាឱ្យសរសើរ ដែល ស.ច.ស. បានលើកយកករណីលើកលែងជា "ភាសាយ៉ាងកំណាច និង ការនិយាយបញ្ឆិតបញ្ឆៀង ដែលសឹងតែគ្មានការលាក់បាំងថា [ខ្លួន] បានចេញដីកាដំណោះស្រាយពីរ ក្នុងគោលបំណងធ្វើឱ្យខូចខាតដល់ដំណើរការក្នុងរឿងក្ដី ០០៤/២ និង ០០៣"[33]។ "ដោយរំឭកដល់សហការី [របស់ពួកគេ] នៅក្នុង អ.ប.ជ. អំពីភារកិច្ចរបស់ពួកគេ តាមក្រមសីលធម៌តុលាការជាតិរៀងៗខ្លួន និង អំពីច្បាប់ទូទៅស្ដីពីការបង្ខូចឈ្មោះ និង បង្កាច់កេរ្ដិ៍" ស.ច.ស. នឹកថា ខ្លួនមានភារកិច្ចត្រូវជូនដំណឹងដល់សហការីខ្លួន នៅក្នុង អ.ប.ជ. ថា ក្រមសីលធម៌តុលាការរបស់កម្ពុជា "ហាមឃាត់នូវការបញ្ចេញយោបល់ជាសាធារណៈដោយចៅក្រម ដែលអាចប៉ះពាល់ដល់កិត្តិយស និង សេចក្ដីថ្លៃថ្នូនៃចៅក្រមដទៃផងដែរ"[34] តាមការត្អូញត្អែរថា ៖

> សហការីយើងនិយាយដោយមិនមានភស្ដុតាងសូម្បីតែបន្តិចនោះ ក្រៅពីការបកស្រាយផ្ទាល់ខ្លួន ដោយលម្អៀងរបស់ពួកគេ ទៅលើព្រឹត្តិការណ៍ គឺចង់សំដៅយ៉ាងច្បាស់ថា ពួកយើងបង្វែរដំណើរការយុត្តិធម៌នោះ គឺជាការចោទប្រកាន់ក្នុងវិជ្ជាជីវៈដ៏អាក្រក់បំផុត ដែលត្រូវបានធ្វើឡើងទៅលើចៅក្រម ហើយក៏មានន័យផងដែរ ជាការចោទប្រកាន់ថា ពួកយើងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[35]។

១០. *សំណួរ៖ (១) ថាតើចៅក្រមជាតិនៃ អ.ប.ជ. មានចេតនាចោទប្រកាន់បែបវិជ្ជាជីវៈ ទៅលើ ស.ច.ស. យូ ប៊ុនឡេង និង Michael Bohlander ពីបទនាំដំណើរការយុត្តិធម៌ទៅផ្លូវអាក្រក់ ដោយការគេចវេះដោយចេតនាពីយន្តការដោះស្រាយជម្លោះដែរឬទេ (២) ហេតុដូចនេះ ថាតើដីកាដំណោះស្រាយរបស់ ស.ច.ស. អាចត្រូវបានចាត់ទុកថាជាការខ្វែងយោបល់គ្នា ដែលមិនបានដោះស្រាយដែរឬទេ ដើម្បីឱ្យគោលជំហរដើមអាចបន្តរដំណើរការរឿងក្ដីទៅដំណាក់កាលជំនុំជម្រះ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយប្រសិនបើបើពួកគេមិនយល់ស្របចំពោះការយល់ឃើញទាំងនេះដែរឬទេ (៣) ថាតើចៅក្រមជាតិនៃ អ.ប.ជ. បានចូលរួមក្នុងការពិភាក្សាសម្រេច និង ព្រាងសេចក្ដីពិចារណា "ជាឯកច្ឆន្ទ" ជាមួយដៃគូអន្តរជាតិរបស់ពួកគេដែរឬទេ ដែលខុសពីការគ្រាន់តែ*

---

[32] សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៣។

[33] សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៩។

[34] សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ១០-១១។

[35] សេចក្ដីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ១២។

*បានទទួលឯកសារជាភាសាខ្មែរសម្រាប់ចុះហត្ថលេខា នៅពេលពិនិត្យ និង ធ្វើការកែប្រែនោះ។*

១១. ***ចៅក្រមជាតិនៃ អ.ប.ជ. ហាក់ដូចជាយល់ស្របថា វិធាន ៧៧(១៣) មិនអាចអនុវត្តបានទេ។*** ដោយឯកច្ឆន្ទ អ.ប.ជ. មិនបានធ្វើការយល់ឃើញ ឬ សន្និដ្ឋានថា តើដីកាដំណោះស្រាយមួយណា ឬ ទាំងពីរមានអានុភាព តាមវិធាន ៧៧(១៣) ប្រសិនបើមិនទទួលបានសំឡេងភាគច្រើនលើសលុបពី អ.ប.ជ.។ អ.ប.ជ. មិនបានធ្វើនិទ្ទេសអំពីវិធាន ៧៧(១៣) នៅក្នុងផ្នែកច្បាប់ជាធរមាន ហើយក៏មិនបានដកស្រង់ពីចំណុចនេះទៅសំអាងនៅក្នុងការវិភាគរួម លើការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នាឡើយ[36]។ អ.ប.ជ. គ្រាន់តែបានថ្លែងនៅក្នុងផ្នែកសម្រេចសេចក្ដីថា តាមវិធាន ៧៧(១៣) សេចក្ដីពិចារណាបិទផ្លូវតវ៉ា[37]។

១២. ចៅក្រមជាតិនៃ អ.ប.ជ. បានយល់ឃើញថា "តាមវិធាន ៧៧(១៣) ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា នៅជាធរមានដូចគ្នា"[38] ដោយមិនបានផ្ដល់សំអាងហេតុ សម្រាប់ការងាកចេញពីវិធីដោះស្រាយរបស់ពួកគេនៅក្នុងរឿងក្ដី ០០៤/២ ដែលសម្រេចតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ តាមវិធាន ៧៧(១៣) ថាជា "ដំណោះស្រាយដ៏សមស្របបំផុត" ដោយសារតែ*ចន្លោះប្រហោង*នៅក្នុងវិធាន ៧៧(១៣) ដែលពួកគាត់បានពិចារណា មិនបានពោលប្រស្រ័យលើដីកាដំណោះស្រាយដែលផ្ទុយគ្នា[39]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាជាងដីកាសម្រេចលើកលែងចោទប្រកាន់ (ដូចគ្នានៅក្នុងរឿងក្ដី ០០៤/២)[40] "ដោយបញ្ជាក់បំភ្លឺ" ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនត្រូវបាន អ.ប.ជ. ច្រានចោលដោយសំឡេងភាគច្រើនលើសលុប ត្រូវមានសុពលភាព តាមវិធាន ៧៧(១៣)(ខ) ហើយត្រូវបញ្ជូនទៅ អ.ជ.ស.ដ.[41]។

១៣. ដោយការកត់សម្គាល់អំពី*ការផ្លាស់ប្ដូរទាំងស្រុង*របស់ពួកគាត់ ពីវិធីដោះស្រាយក្នុងរឿងក្ដី០០៤/២ ដែលហាក់ដូចជាយល់ស្របជាមួយទឡ្ហីករណ៍របស់លោក មាស មុត ដែលថា ដីកាដំណោះស្រាយ

---

[36] *សូមមើល* សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៧៩-៨៣, ៩២-១១០។

[37] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ ទំព័រ ៥៦។

[38] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៥-១១៨។

[39] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៣០២ (vi)-(viii)។

[40] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៦៨៣, ៦៨៥-៦៨៧, ៦៩៤។

[41] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៦១។

ទាំងពីរ គួរមានអានុភាព ប្រសិនបើវិធាន ៧៧(១៣) ត្រូវអនុវត្ត[42] នោះ ស.ច.ស. មិនបានព្យាយាម "បកស្រាយសំអាងហេតុ ដែលធ្វើឱ្យចៅក្រមជាតិ បែរជាប្រើប្រាស់វិធីដោះស្រាយ និង ពាក្យពេចន៍ផ្សេងនៅក្នុងសំណុំរឿង ០០៣ និង បកស្រាយថា តើចេតនាពិតប្រាកដរបស់ពួកគេគឺជាអ្វីនោះដែរ"[43]។ ប៉ុន្តែ ស.ច.ស. គឺ "ពេញចិត្តទាំងស្រុងថា ការនិយាយថាដីកាដំណោះស្រាយទាំងពីរមានសុពលភាព ពិតជា*មិនមែន*មានន័យថា យល់ព្រមឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជូនទៅ អ.ជ.ស.ដ. ឡើយ ព្រោះពួកគាត់ខ្លួនឯងបានបង្គាប់ឱ្យដាក់សំណុំរឿងចូលទៅក្នុងបណ្ណាសារ"[44]។ ពួកគេបានយល់ឃើញថា ចៅក្រមជាតិនៃ អ.ប.ជ. ចូលរួមជាមួយសហការីអន្តរជាតិរបស់ខ្លួន ក្នុងការពិចារណាថា គោលជំហរដើមត្រូវអនុវត្ត នោះ "បញ្ហាថាតើវិធាន ៧៧(១៣) ត្រូវអនុវត្តដោយផ្ទាល់ដែរឬអត់ ទៅលើសេណារីយ៉ូអរូបច្ចុប្បន្ននេះ ចាំបាច់ត្រូវតែដោះស្រាយ" ដោយសារតែរឿងក្តីត្រូវបន្តទៅមុខ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[45]។

១៤. *__សំណួរ៖__ (១) ថាតើចៅក្រមជាតិនៃ អ.ប.ជ. ពិចារណាថា វិធាន ៧៧(១៣) ត្រូវអនុវត្តដែរឬទេ ចំពោះដីកាដំណោះស្រាយដែលផ្ទុយគ្នា ហើយប្រសិនបើត្រូវអនុវត្ត (២) តើពួកគេត្រូវសម្រុះសម្រួលបែបណា ចំពោះការតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ ជាជាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៧(១៣) នៅក្នុងករណីមួយ ខណៈពេលដែលសម្រេចនៅក្នុងករណីមួយទៀតថា ដីកាដំណោះស្រាយទាំងពីរ មានតម្លៃស្មើគ្នា នៅតែមានដូចគ្នា តាមវិធាន ៧៧(១៣)នោះ?*

១៥. ***ចៅក្រមជាតិនៃ អ.ប.ជ. ទំនងជាយល់ស្របថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ត្រូវអនុវត្ត***។ ដោយឯកច្ឆន្ទ អ.ប.ជ. បានយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបានទេ ដោយពិចារណាថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* មិនអាចអនុវត្តចំពោះសេចក្តីសម្រេចថា តើត្រូវបញ្ជូនរឿងទៅជំនុំជម្រះដែរឬទេ ព្រោះវាកើតចេញពីសច្ចធារណ៍នៃនិរទោស "ដែលតាមសច្ចធារណ៍នេះ មាស មុត

---

[42] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះ ថ្ងៃទី៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៤១-៤៦។ *សូមមើលផងដែរ ខាងក្រោម* កថាខណ្ឌ ១៨។

[43] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៣៤។

[44] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៣៤។

[45] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២២។

នៅតែគ្មានទោស បើទោះបីជាត្រូវបានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះក្ដី ហើយនៅតែមិនមានទោស លុះត្រាតែមានការសម្រេចថាមានពិរុទ្ធភាព”[46]។ ដោយយល់ឃើញថា ខ្លួនបានបញ្ជាក់បំភ្លឺរួចហើយ ពីច្បាប់ដែលចែងអំពីដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/២[47] នោះ អ.ប.ជ. បានយល់ឃើញថា ការបកស្រាយក្នុងន័យទូលាយទៅលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍របស់លោក មាស មុត គឺមិនត្រូវបានធានា “ដើម្បីជៀសវាងព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌[របស់គាត់]ទេ”[48]។ ប៉ុន្តែ ផ្ទុយទៅវិញ ចៅក្រមជាតិនៃ អ.ប.ជ. ហាក់ដូចជាអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ទោះបីជាពិចារណាដោយយល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់គ្រប់គ្រងទៅលើដីកាដំណោះស្រាយដែលមានទម្ងន់ស្មើគ្នាផ្សេងទៀតក៏ដោយ។

១៦. ដោយការសន្និដ្ឋានថា រឿងក្ដី ០០៣ គួរត្រូវបានដាក់បញ្ចូលទៅក្នុងបណ្ណសារ[49] ចៅក្រមជាតិនៃ អ.ប.ជ. បានអនុម័តយកយ៉ាងមានប្រសិទ្ធភាព នូវទឡ្ហីករណ៍បណ្ដឹងឧទ្ធរណ៍របស់លោក មាស មុត ជាសំខាន់ ដោយយល់ស្របជាមួយខ្លឹមសារ និង លទ្ធផល ដែលថា ៖ (ក) វិធាន ៧២ មិនអាចអនុវត្តបានទេ ដោយសារតែ ស.ច.ស. មិនចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា (ខ) វិធាន ៧៧(១៣) មិនអាចអនុវត្តបានទេ ដូចនេះដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានឧត្តមភាពជាស្វ័យប្រវត្តិលើដីកាសម្រេចលើកលែងចោទប្រកាន់ និង (គ) គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស តម្រូវថាដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៧. ចៅក្រមជាតិនៃ អ.ប.ជ. បានអនុម័តយកយ៉ាងមានប្រសិទ្ធភាព នូវទឡ្ហីករណ៍របស់លោក មាស មុត អំពីវិធាន៧២ ក្នុងការពិចារណាថា ៖ (ក) “[ស.ច.ស.] ទាំងពីរនាក់ បានយល់ស្របគ្នារក្សាទុកករណីខ្វែងយោបល់គ្នានៅក្នុងការិយាល័យរបស់ខ្លួន ព្រមទាំងបានព្រមព្រៀងគ្នាពុំនាំយកការខ្វែងគំនិតនោះមកចំពោះមុខ [អ.ប.ជ.]” (ខ) “ពួកគេបានយល់ព្រមពុំអនុវត្តតាមអ្វីដែលមានចែង

[46] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៧៧។

[47] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៧៥។

[48] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៧៧។

[49] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៨។

ក្នុងវិធាន ៧២ ទេ”[50] ហើយ (គ) “ដូច្នេះ [អ.ប.ជ.] ពុំអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងវិធាន ៧២ ឡើយ”[51]។ លោក មាស មុត បានលើកទឡ្ហីករណ៍ថា វិធាន ៧២ មិនអាចអនុវត្តឡើយ ព្រោះ “ស.ច.ស. មិនបានប្ដឹងទៅ អ.ប.ជ. អំពីសំណើតាមវិធាន ៧២ សុំឱ្យដោះស្រាយការយល់ឃើញផ្ទុយគ្នារបស់ខ្លួន នៅមុនពេលចេញដីកាដំណោះស្រាយឡើយ”[52]។

១៨. ចៅក្រមជាតិនៃ អ.ប.ជ. បានអនុម័តយកយ៉ាងមានប្រសិទ្ធភាពនូវទឡ្ហីករណ៍របស់លោក មាស មុត អំពីវិធាន ៧៧(១៣) ក្នុងការពិចារណាថា “តាមវិធាន ៧៧(១៣) ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និង មានសុពលភាពដូចគ្នា”[53]។ លោក មាស មុត បានលើកទឡ្ហីករណ៍ថា ការអនុវត្តវិធាន ៧(១៣) នឹងនាំទៅដល់លទ្ធផលដែលខុសឆ្គង និង បណ្ដាលឱ្យមានព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោក មាស មុត (រួមទាំងសច្ចធារណ៍នៃនិរទោស) ដោយសារតែដីកាដំណោះស្រាយទាំងពីរ នឹងមានអានុភាព (ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះមានអានុភាព ដែលផ្ទុយទៅនឹងគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*)[54]។

១៩. ចៅក្រមជាតិនៃ អ.ប.ជ. បានអនុម័តយកយ៉ាងមានប្រសិទ្ធភាព នូវទឡ្ហីករណ៍របស់លោក មាស មុត អំពីគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដោយការពិចារណាថា “[ស.ច.ស.] ទាំងពីរ មានឋានៈស្មើគ្នា ហើយយោងតាមអញ្ញត្រកម្មនៃសច្ចធារណ៍នៃនិរទោស ច្បាប់ជាធរមានពុំអនុញ្ញាតឱ្យ [អ.ប.ជ.] សម្រេចថា កិច្ចរបស់ [ស.ច.ស.] ណាម្នាក់ មានឧត្តមភាពនោះទេ”[55]។ លោក មាស មុត បានលើកទឡ្ហីករណ៍ថា (ក) ៖ “ស.ច.ស. ទាំងពីរ មានឋានៈ

---

[50] *ប្រៀបធៀប*សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៣ *ជាមួយ*បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៦។

[51] *ប្រៀបធៀប*សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៣ *ជាមួយ*បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៧។

[52] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៦-៣៧។

[53] *ប្រៀបធៀប*សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៥ *ជាមួយ*បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-៤៣។

[54] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-៤៦។

[55] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៦ *ជាមួយ*បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៤, ៣៧។

ស្មើគ្នា”[56] (ខ) “ការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ មិនមានអានុភាពខ្ពស់ជាង ឬ ទាបជាងការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស ម្នាក់ទៀតឡើយ”[57] និង (គ) ដោយមិនមានការយល់ឃើញដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. ដែលថា ស.ច.ស.ជ. មានកំហុសឆ្គង ឬ រំលោភបំពានទៅលើឆន្ទានុសិទ្ធិ ដែលជាកត្តាកំណត់គ្រឹះ ចំពោះការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ តាមគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* នោះ“ដីកាដំណោះស្រាយដែលបង្គាប់ឱ្យលើកលែងចោទប្រកាន់ក្នុងរឿងក្តី មានអានុភាពលើដីកាដំណោះស្រាយដែលបង្គាប់ឱ្យបញ្ជូនរឿងទៅជំនុំជម្រះ”[58]។

២០. ដោយពិចារណាថា ចៅក្រមជាតិនៃ អ.ប.ជ. អាចមានចេតនាអនុម័តយកទឡ្ហីករណ៍មួយចំនួនរបស់លោក មាស មុត ទើប ស.ច.ស. បានយល់ឃើញថា វា“ជាការអះអាងដែលទាល់ច្រកយ៉ាងពិសេស ក្នុងការនិយាយសំដៅថា ចៅក្រមជាតិបានផ្លាស់ប្តូរទស្សនៈរបស់ខ្លួន សម្រាប់សំណុំរឿង 00៣ បន្ទាប់ពីស្តាប់ទឡ្ហីករណ៍ក្នុងសំណុំរឿង 00៣ ដែលពួកគេអាច និង គួរតែបានធ្វើការពិចារណារួចទៅហើយក្នុងសំណុំរឿង 00៤/២”[59]។ ពួកគេបានពិចារណា “គោលការណ៍ដែលថាសំណុំរឿងដូចគ្នា ចាំបាច់ត្រូវអនុវត្តដូចគ្នា” និង បានសន្មតថា “ចៅក្រមដដែល នឹងធ្វើការសម្រេចលើបញ្ហាគតិយុត្តិស្រដៀងគ្នា តាមវិធីដូចគ្នា” វៀរលែងតែទស្សនៈរបស់ពួកគេបានផ្លាស់ប្តូរ (ហើយពួកគេបានថ្លែងពីសំអាងហេតុ) ឬ ច្បាប់បានផ្លាស់ប្តូរ (ហើយតម្រូវឱ្យមានចម្លើយមួយផ្សេងទៀត)[60]។

២១. *<u>សំណួរ</u>៖ (១) តើចៅក្រមជាតិនៃ អ.ប.ជ. មានចេតនាក្នុងការអនុម័តយកទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត ដែរឬទេ ក្នុងការដកចេញពីវិធីដោះស្រាយរបស់ពួកគេ ក្នុងរឿងក្តី 00៤/២ និង ក្នុងការពិចារណាក្នុងរឿងក្តី 00៣ ថា ដោយសារតែដីកាដំណោះស្រាយទាំងពីរ មានតម្លៃដូចគ្នា តាមក្របខណ្ឌ អ.វ.ត.ក. នោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនអាចមានអានុភាពលើ*

[56] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ២-៣, កថាខណ្ឌ ៣៤, ៣៧។

[57] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ២-៣, ៦៤, ៦៩។

[58] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ២-៣, កថាខណ្ឌ ២, ៤៩-៦៦, ៦៩-៧១។

[59] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង 00៣ កថាខណ្ឌ ៣៣-៣៤។

[60] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង 00៣ កថាខណ្ឌ ៣៣-៣៤។

*ដីកាសម្រេចលើកលែងចោទប្រកាន់ ហើយបញ្ជូនទៅ អ.ជ.ស.ដ. និង ប្រសិនបើពួកគាត់មិនមានចេតនាដូច្នោះទេ (២) តើសច្ចធារណ៍នៃនិរទោសអាចត្រូវបានចាត់ទុកថាជាមូលដ្ឋានស្របច្បាប់ ក្នុងការដាក់បញ្ចូលរឿងក្ដីទៅក្នុងបណ្ណាសារឬទេ ប្រសិនបើផលវិបាករបស់វា គឺគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ មិនត្រូវអនុវត្តនោះ។*

២២. ***ចៅក្រមជាតិនៃ អ.ប.ជ. ហាក់ដូចជាយល់ស្របថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលទេ។*** ដោយឯកច្ឆន្ទ អ.ប.ជ. មិនបានឈានដល់សេចក្ដីសន្និដ្ឋានលើអង្គសេចក្ដីនៃបញ្ហាចុងក្រោយនៅចំពោះមុខខ្លួនឡើយ ៖ ថាតើលោក មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ ចំពោះអំពើសាហាវយង់ឃ្នងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះហើយទើបត្រូវស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.។ ទោះបីជាចៅក្រមជាតិនៃ អ.ប.ជ. មិនបានផ្ដល់ការវិភាគពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ទៅលើលោក មាស មុត ក្ដី[61] ក៏ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានយល់ឃើញថា គាត់ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត[62] បើទោះបីជាបាន "ពិចារណាឃើញថា ពុំចាំបាច់ពិនិត្យទៅលើខ្លឹមសារនៃការអះអាងរបស់ [ស.ព.អ.] ដែលថា ការខកខានពុំបានវាយតម្លៃទៅលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង បានធ្វើឱ្យអានុភាពជាកត្តាកំណត់ទៅលើការពិនិត្យរបស់ [ស.ច.ស.ជ.] ចំពោះយុត្តាធិការបុគ្គលនោះ"[63]។

២៣. ចៅក្រមជាតិនៃ អ.ប.ជ. មិនបានបញ្ចូលទស្សនៈរបស់ពួកគាត់ ដែលបានលើកឡើងនៅក្នុងរឿងក្ដី ០០៣ និង ០០៤/២ ដែលថា អ.វ.ត.ក. ពុំមានយុត្តាធិការបុគ្គលទៅលើលោក មាស មុត ដូចជា ៖ (ក) ការយល់ស្របរបស់ពួកគាត់ជាមួយ ស.ព.ជ. ដែលថា រឿងក្ដី ០០៣ មិនគួរត្រូវបានចោទកាន់ទោសឡើយ ដោយសារតែ ស.ព.អ. បានបំពេញកិច្ចជាឯកតោភាគី ក្នុងការបើកកិច្ចស៊ើបសួរ[64] (ខ) ការប្រកាសរបស់ពួកគាត់នៅក្នុងពេលស៊ើបអង្កេតដែលថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលទៅ

---

[61] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១១៣-១១៨។

[62] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៣៤០។

[63] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៤៣។

[64] ឧបសម្ព័ន្ធ ១៖ សំណៅសាធារណៈមានកោសលុប សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៨។

លើលោក មាស មុត ឡើយ[65] និង (គ) ការបញ្ជាក់អះអាងរបស់ពួកគាត់ក្នុងរឿងក្តី ០០៤/២ ដែលថា រឿងក្តី ០០៣ និង ០០៤ មិនគួរត្រូវបានស៊ើបអង្កេតឡើយ និង ដោយយល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តី ០០៤/២ គ្មានសុពលភាព ដោយផ្អែកលើមូលដ្ឋាននេះ[66]។ នៅមានទៀត បន្ទាប់ពីការចេញសេចក្តីពិចារណាក្នុងរឿងក្តី ០០៣ ពួកគាត់បានបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ទាំងអស់* ដោយផ្អែកលើមតិរបស់ខ្លួនដែលថា រឿងក្តី ០០៣ គួរត្រូវដាក់បញ្ចូលទៅក្នុងបណ្ណសារ[67]។

២៤. *<u>សំណួរ៖</u> តើចៅក្រមជាតិនៃ អ.ប.ជ. មានចេតនាក្នុងការសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬទេ បើទោះបីជាពួកគាត់ពិចារណាថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលទៅលើលោក មាស មុត?*

២៥. ***ចៅក្រមជាតិនៃ អ.ប.ជ. ត្រូវតែបញ្ជាក់បំភ្លឺអំពីការយល់ឃើញរបស់ខ្លួនចំពោះសេចក្តីពិចារណា។*** អ.ប.ជ. មិនអាចបញ្ជូនលោក មាស មុត ទៅជំនុំជម្រះទេ[68] លើកលែងតែ យ៉ាងហោចណាស់ចៅក្រមជាតិពីរនាក់ក្នុងចំណោមចៅក្រមជាតិទាំងបីនាក់នៃ អ.ប.ជ. បានប៉ុនប៉ងដូច្នេះ។ តាមពិតប្រសិនបើ មតិរបស់ចៅក្រមជាតិខ្លះ ឬ របស់ចៅក្រមជាតិទាំងអស់នៃ អ.ប.ជ. ដែលថា ដីកាបញ្ជូន

---

[65] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសារឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៦-២៩។ សាលដីការបស់អង្គបុរេជំនុំជម្រះ ១) បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំមោឃភាពចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ទាក់ទងសំណើសុំទាំងប្រាំបួនរបស់ មាស មុត សុំមោឃភាព កថាខណ្ឌ ៩៦, ១៣៩។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៧ ឯកសារ D87/2/1.7/1/1/7 យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៧២។

[66] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៣០២។

[67] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D269/4 កថាខណ្ឌ ៤៤-៤៥។

[68] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ២១។

រឿងទៅជំនុំជម្រះ មានអានុភាព *និង* ថា គោលជំហរដើមត្រូវអនុវត្តមែន ដូច្នោះ ចៅក្រមជាតិនៃ អ.ប.ជ. គួរតែនិយាយអ៊ីចឹងឱ្យច្បាស់លាស់ និង កុំស្រពិចស្រពិល ហើយត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅ អ.ជ.ស.ដ.។ យ៉ាងណាក្តី ប្រសិនបើពួកគាត់ទទួលស្គាល់ទឡ្ហីករណ៍ដែលលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត និង យល់ស្របថា មិនអាចញែកដីកាសម្រេចលើកលែងចោទប្រកាន់ចោលដោយឡែក នោះគឺពិតជា*ការភ័យខ្លាចលើការសម្រេច* (analysis paralysis) ដែលចាំបាច់ត្រូវតែដោះស្រាយ តាមរយៈការបញ្ចប់ ការបោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ។ ទោះជាតាមមធ្យោបាយណាក្តី ក៏ អ.ប.ជ. ចាំបាច់ត្រូវចេញសេចក្តីសម្រេចស្ថាពរមួយនៅក្នុងដំណើរការនីតិវិធីមុនពេលជំនុំជម្រះ ដោយសម្រេចលើរឿងក្តី ០០៣ ក្នុងវិធីមួយ ដែលធ្វើឱ្យមានសច្ចភាព និង ភាពច្បាស់លាស់ផ្នែកច្បាប់ ហើយបញ្ចប់ការជាប់គាំងផ្នែកតុលាការ។ “*ដំណើការនីតិវិធីប្រឆាំង មាស មុត នឹងស្ថិតនៅជាការរង់ចាំសម្រេចជារៀងរហូត ដោយមិនមានដំណោះស្រាយ ប្រសិនបើស្ថានភាពបន្ទាប់ពីសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ... គឺជាសភាពចុងក្រោយនោះ*”[69]។

**ខ. បើទោះបីជា អ.ប.ជ. សម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី ក៏ក្របខណ្ឌ អ.វ.ត.ក. មិនតម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ និង ត្រូវបញ្ជូនទៅ អ.ជ.ស.ដ. ឡើយ**

២៦. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា ក្របខណ្ឌ អ.វ.ត.ក. “តម្រូវយ៉ាងច្បាស់លាស់ថា រឿងក្តី និង សំណុំរឿងត្រូវបញ្ជូនទៅ អ.ជ.ស.ដ. ដើម្បីធ្វើការជំនុំជម្រះ ផ្អែកលើការយល់ឃើញជាឯកច្ឆន្ទរបស់ អ.ប.ជ. ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព” និង ថា “នៅតែត្រូវ” បញ្ជូនទៅជំនុំជម្រះ បើទោះបីជា អ.ប.ជ. មិនអើពើចំពោះការយល់ឃើញ “ជាឯកច្ឆន្ទ” ក្តី[70]។ បើទោះបីជាចៅក្រមជាតិនៃ អ.ប.ជ. មានចេតនាថា ត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយការយល់ដឹងពេញលេញពីសេចក្តីពិចារណាជាឯកច្ឆន្ទក្តី ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយ ស.ច.ស. ម្នាក់ មិនអាចមានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ ដែលចេញដោយ ស.ច.ស. ម្នាក់ទៀតបានឡើយ បើតាមក្របខណ្ឌ អ.វ.ត.ក.។ ប្រសិនបើចៅក្រមជាតិនៃ អ.ប.ជ. ពិចារណាថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* មិនអាចអនុវត្តបាន

[69] *សូមមើល* សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៦។

[70] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២២។

ទេ នោះដីកាដំណោះស្រាយទាំងពីរនៅតែបន្តលងបន្លាចលោក មាស មុតជារៀងរហូត លើកលែងតែ និង រហូតដល់រឿងក្តី ០០៣ ត្រូវបានបញ្ចប់ បោះត្រា និង ដាក់បញ្ចូលទៅក្នុងបណ្ណាសារដោយ អ.ប.ជ.[71]។ ប្រសិនបើចេតនារបស់ពួកគាត់ថាត្រូវរក្សាទុកភាពជាប់គាំងឱ្យគាំងនៅ នោះ ពួកគាត់ត្រូវតែបញ្ជាក់វាឱ្យច្បាស់លាស់ ដើម្បីឱ្យភាគីនានាអាចស្វែងរកការកែខៃពី អ.ជ.ត.ក. (ជាកន្លែងដែលអាចដោះស្រាយនូវចម្លើយបានយ៉ាងល្អ)[72] ឬ ពី ស.ច.ស.[73]។

២៧. ***គោលជំហរដើមមិនអាចអនុវត្តបានទេ។*** គោលជំហរដើមដែលចែងថា "កិច្ចស៊ើបអង្កេតត្រូវបន្តទៅមុខ" កាលណា អ.ប.ជ. ខកខានមិនបានសំឡេងភាគច្រើនលើសលុបលើការខ្វែងយោបល់គ្នារបស់ ស.ច.ស. នោះ *មិន*អាចអនុវត្តបាន ចំពោះដីកាដំណោះស្រាយដែលផ្ទុយគ្នាឡើយ[74]។ ទោះបី អ.ប.ជ. បានពណ៌នាដោយឯកច្ឆន្ទ ចំពោះគោលជំហរដើមថា"ជាមូលដ្ឋាន និង កត្តាកំណត់"[75] ក្តី ក៏ចៅក្រមជាតិនៃ អ.ប.ជ. ហាក់ដូចជាយល់ស្របថា មិនអាចអនុវត្តបានទេ[76] ដោយការយល់ឃើញយ៉ាងច្បាស់លាស់ថា ដោយសារតែ ស.ច.ស. ទាំងពីរនាក់ បានយល់ស្របគ្នាចុះការខ្វែងយោបល់នៅក្នុងការិយាល័យរបស់ខ្លួន នោះ "អ.ប.ជ. ពុំអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួន ... តាមវិធាន ៧២ នៃវិធានផ្ទៃក្នុងឡើយ"[77]។ ការយល់ឃើញរបស់ពួកគេនេះ គឺស្របគ្នាជាមួយយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដែលអះអាងបញ្ជាក់ថា ពាក្យ "ការស៊ើបអង្កេតត្រូវបន្ត" មានន័យថាការខ្វែងយោបល់គ្នារវាង ស.ច.ស. មិនត្រូវឈានទៅដល់ការជាប់គាំងមួយណាក្នុង*ការស៊ើបអង្កេត* របស់ពួកគេ ដែល

---

[71] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណាសារ កថាខណ្ឌ ៦០-៦៩។

[72] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៧១។

[73] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៤២។

[74] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ២៣ ដែលដកស្រង់មាត្រា ៥(៤), ៧(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[75] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៩៨។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ១១២។

[76] *សូមមើលខាងលើ* កថាខណ្ឌ ៧-៩។

[77] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៣។

ត្រូវបញ្ចប់នៅពេលដែលពួកគេចេញដីកាដំណោះស្រាយមួយ[78]។

២៨. ប្រាកដណាស់ថា អ.ប.ជ. បានយល់ដឹងអំពីទឡ្ហីករណ៍របស់លោក មាស មុត ពីរបៀប ដែលយន្តការដោះស្រាយជម្លោះតាមវិធាន ៧២ នឹងមិនអាចដោះស្រាយចំពោះដីកាដំណោះស្រាយដែលផ្ទុយគ្នា សូម្បីតែដីកាដំណោះស្រាយទាំងនេះត្រូវបានចាត់ទុកដូចជាការខ្វែងយោបល់គ្នា ដែលមិនអាចដោះស្រាយបានក្តី[79]។ ដីកាដំណោះស្រាយទាំងពីរ នឹងមានអានុភាព តាមវិធាន ៧២(៤) ដោយរំលោភបំពានទៅលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[80] នោះបញ្ហាដែល ស.ច.ស. បានយល់ដឹង និង ព្រួយបារម្ភខ្លាំង ដល់ថ្នាក់ស្វែងរកសំណើសុំឱ្យពិចារណានានាលើបញ្ហាថា តើត្រូវផ្អាកកិច្ចស៊ើបសួររបស់ខ្លួនដែរឬយ៉ាងណា[81]។ ការទុកចោលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនអាចជំទាស់តវ៉ាបាន ឱ្យនៅតាមលងបន្លាចលោក មាស មុត គឺ "មិនស្របនឹងតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋឡើយ"[82]។

២៩. បើទោះបីជាគោលបំណង និង គោលដៅនៃកិច្ចព្រមព្រៀងគឺ *"[នាំ] មកជំនុំជម្រះ"* នូវមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតក្តី ក៏ភាគីនៃកិច្ចព្រមព្រៀង មិនបាន និង មិនអាចយល់ស្របលើគោលជំហរដើម ក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ

---

[78] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៥។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ការបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D266/7 ("ការឆ្លើយតបរបស់ មាស មុត") កថាខណ្ឌ ៤៧-៤៨។ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ..ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ២៧៥។

[79] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២៧។

[80] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៧។ ការឆ្លើយតបរបស់ មាស មុត កថាខណ្ឌ ២៦។

[81] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និង ផលប៉ះពាល់លើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 ("សំណើរបស់ ស.ច.ស. សុំមតិយោបល់") កថាខណ្ឌ ១, ៥៤។

[82] សំណើរបស់ ស.ច.ស. សុំមតិយោបល់ កថាខណ្ឌ ៥៤។

នៅពេលដែលមានការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងពេលជាមួយគ្នានោះ[83]។ ភាគីនៃកិច្ចព្រមព្រៀង មានការទទួលស្គាល់ពេញលេញអំពី "គម្លាតនិទណ្ឌភាពជាខ្លាំង" ដែលបណ្តាលមកពីយុត្តាធិការបុគ្គល មានកម្រិតរបស់ អ.វ.ត.ក.[84] និង អំពីលទ្ធភាពដែលថា ស.ច.ស. ម្នាក់អាចនឹងបញ្ជូនរឿងទៅជំនុំជម្រះ នាពេលដែល ស.ច.ស. ម្នាក់ទៀត អាចនឹងលើកលែងចោទប្រកាន់[85]។ ម៉្យាងវិញទៀត ពួកគេមិនអាចយល់ស្របថា រឿងក្តីត្រូវតែបន្តទៅជំនុំជម្រះ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលមានការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងពេលជាមួយគ្នា ដោយសារការអនុវត្តបែបនេះនឹងធ្វើឱ្យដំណើរការនីតិវិធីរបស់ អ.វ.ត.ក. បាត់បង់នូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដែលស្របតាមរដ្ឋធម្មនុញ្ញ[86]។

៣០. ***វិធាន ៧៧(១៣) មិនអាចអនុវត្តបានទេ***។ បើទោះបីជា អ.ប.ជ. ពិតជាបានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តីមែន ក៏វិធាន ៧៧(១៣) មិនអាចអនុវត្តបានទេ នៅពេលដែល ស.ច.ស. បានចេញដីកាដំណោះស្រាយផ្ទុយគ្នា[87]។ ប្រសិនបើអនុវត្តវិធាន ៧៧(១៣)(ក) អាចអនុវត្តបានចំពោះដីកាសម្រេចលើកលែងចោទប្រកាន់ និង វិធាន ៧៧(១៣)(ខ) អាចអនុវត្តបានចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះការអនុវត្តរួមទាំងពីរ នាំទៅដល់លទ្ធផលដែលមិនសមហេតុផល និង បណ្តាលឱ្យមានព្យសនកម្ម ដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត ដោយសារតែដីកាដំណោះស្រាយទាំងពីរ នឹងនៅបន្តតាមលងបន្លាចលោក មាស មុត ជារៀងរហូត[88]។ ផ្ទុយទៅវិញ បើអនុវត្តវិធាន ៧៧(១៣)(ខ) ដើម្បីឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពជាស្វ័យប្រវត្តិលើដីកាសម្រេចលើកលែងចោទប្រកាន់ នោះគឺមិនគ្រាន់តែរំលោភបំពានទៅលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*

---

[83] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ២៥។ ការឆ្លើយតបរបស់ មាស មុត កថាខណ្ឌ ១៨។

[84] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ១៨-១៩, ២៥។

[85] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៣-៣៤។

[86] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៦៨។

[87] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ២៣, ៣០។

[88] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-៤៦។

ដែលស្របតាមរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ[89] ប៉ុន្តែថែមទាំងធ្វើឱ្យ ស.ច.ស.ជ. មានឋានៈទាបជាង ស.ច.ស.អ. ដោយខុសឆ្គងថែមទៀតផង ដែលជាការដកហូតនូវឋានៈស្មើគ្នា និង សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់គាត់[90]។ ដោយសារតែឋានៈស្មើគ្នារបស់គាត់ តាមក្របខណ្ឌ អ.វ.ត.ក. នោះអវត្តមាននៃការយល់ឃើញដោយសំឡេងភាគច្រើនលើសលុបថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុសឆ្គង ឬ រំលោភបំពានជាកត្តាកំណត់ជាមូលដ្ឋាន ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ទេ នោះដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចទុកចោលបាននោះឡើយ[91]។

៣១. ***គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទអាចអនុវត្តបាន។*** គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស ដែលត្រូវអនុវត្តនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី រួមទាំងនៅពេលចេញសេចក្តីសម្រេចថា តើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់នៅដំណាក់កាលមុនពេលជំនុំជម្រះ[92]។ ដោយសារតែការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការអនុវត្តច្បាប់ ឬ ការចេញដីកាដំណោះស្រាយមួយរបស់ ស.ច.ស. ម្នាក់ មិនមានអានុភាពខ្ពស់ជាង ឬ ទាបជាង ស.ច.ស. ម្នាក់ផ្សេងទៀត ពីព្រោះថា អ.ប.ជ. មិនបានយល់ឃើញដោយសំឡេងភាគច្រើនលើសលុបថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុសឆ្គង ឬ រំលោភបំពានលើកត្តាកំណត់ជាមូលដ្ឋាន នៃការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ ដែលនឹងរារាំងទៅដល់ការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* នោះដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវមានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំ

---

[89] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ *រឿងក្តី នួន ជា និងអ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[90] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣២-៤៦, ៦២-៧០។ ចម្លើយរបស់ មាស មុត កថាខណ្ឌ ១៥-២០។

[91] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៤៥-៥៧។

[92] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ៣០។ *រឿងក្តី នួន ជា និងអ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) ) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣១០។ *រឿងក្តី នួន ជា និងអ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៤៥ និង ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឡើងដោយ នួន ជា និអ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។

ជម្រះ[93]។ ចៅក្រមជាតិនៃ អ.ប.ជ. *មិនបាន* មើលរំលង"វិធាន ៧៧(១៣)(ខ) និង គោលជំហរដើម"ឡើយ[94] ប៉ុន្តែហាក់ដូចជាអនុម័តយកទឡ្ហីករណ៍របស់លោក មាស មុត ដែលថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស ដែលតម្រូវថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[95]។ ប្រសិនបើពួកគាត់មិនពិចារណាថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* អនុវត្តបានទេ នោះនឹងមាន*ការភ័យខ្លាចលើការសម្រេច* (analysis paralysis) ដែលត្រូវតែដោះស្រាយដោយការបញ្ចប់ ការបោះត្រា និង ការដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ។

៣២. ***អ.ប.ជ. មានសិទ្ធិអំណាច និង ភារកិច្ច បញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តីទៅក្នុងបណ្ណសារ។*** ការបែកគ្នារបស់ អ.ប.ជ. *អាច*បណ្តាលឱ្យមានការបញ្ចប់ (ការលើកលែងចោទប្រកាន់យ៉ាងមានប្រសិទ្ធភាព) នៃរឿងក្តី[96]។ អ.ជ.ត.ក. បានយល់ឃើញថា ការបញ្ចប់រឿងក្តី ០០៤/២ គឺសមស្របដោយការពិចារណាទៅលើការស៊ើបអង្កេតរយៈពេល ១៣ ឆ្នាំ និង ការខ្វែងយោបល់គ្នាពីយុត្តាធិការបុគ្គល ការខកខានរបស់ អ.ប.ជ. មិនបាន"ផ្តល់នូវសេចក្តីសម្រេចជាក់ស្តែង" ទៅលើដីកាដំណោះស្រាយដែលខុសច្បាប់របស់ ស.ច.ស. និង កង្វះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព (មានន័យថាគោលជំហរដើមមិនអាចអនុវត្តបាន)[97]។ អ.ប.ជ. ក៏មានករណីកិច្ចដើម្បីបញ្ចប់ បោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ក្នុងបណ្ណសារ ជាឧបាស្រ័យចំពោះការរំលោភនីតិវិធីពី មិនឱ្យមានការរំលោភបំពានតទៅទៀតលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការបញ្ចប់ដំណើរការនីតិវិធីក្នុងពេលវេលាសមស្រប និង ដើម្បីជៀសវាងកំហុសឆ្គោះឆ្គាយលើយុត្តិធម៌[98]។

---

[93] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ២-៣។

[94] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ៣០។

[95] *សូមមើលខាងលើ* កថាខណ្ឌ ១៥-២១។

[96] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២៩។

[97] សាលដីការបស់ អ.ជ.ត.ក. កថាខណ្ឌ ៥៣, ៦៧-៦៨, ៧១។

[98] *សូមមើល* សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ កថាខណ្ឌ ៤៨-៥០, ៦០-៦៩។

៣៣. នីតិវិធីព្រហ្មទណ្ឌកម្ពុជា *ពិតជា*បានប្រមើលមើលពីការបញ្ចប់ដំណើរការនីតិវិធីទេ[99]។ អ.ជ.ត.ក. បានពន្យល់ថា បើទោះបីជាបណ្ដឹងព្រហ្មទណ្ឌ មិនអាច "រំលត់" បាន លើកលែងតែក្នុងករណីដែលជនជាប់ចោទស្លាប់ ការផុតអាជ្ញាយុកាល ការទទួលបានការលើកលែងទោស និរាករណ៍នៃច្បាប់ និង *អាជ្ញាអស់ជំនុំ* នោះ ច្បាប់កម្ពុជា ៖ "ចែងអំពីអំណាចក្នុងការ "បង្អង់" ឬ "ផ្អាក" ដំណើរការនីតិវិធីក្នុងកាលៈទេសៈជាក់លាក់មួយចំនួន *ដោយសារតែជាឧបសគ្គ* ចំពោះដំណើរការនីតិវិធី..."[100]។

៣៤. ការមិនយល់ស្របគ្នា ដែលកើតមានជាទូទៅរវាង ស.ព.អ. ស.ច.ស. អ.ប.ជ. និង ប្រហែលជា អ.ជ.ស.ដ. ផងដែរ ពីបញ្ហាថា តើលោក មាស មុត គួរត្រូវបញ្ជូនទៅជំនុំជម្រះដែរឬទេនោះ គឺជាឧបសគ្គដែលពិបាកចំពោះដំណើរការនីតិវិធី[101]។ ការយល់ឃើញ (ដោយភាន់ច្រឡំ) ថា ស.ច.ស. បានរំលោភនីតិវិធី[102] ប្រសិនបើ អ.ប.ជ. ពេលនេះ ត្រូវបញ្ជូនរឿងក្ដី ០០៣ ទៅជំនុំជម្រះ ដោយដឹងថាសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានដំណើរការនីតិវិធីឆាប់រហ័ស នឹងត្រូវព្យួរទុកចោល ព្រោះតែការខ្វែងយោបល់គ្នាដែលមិនអាចផ្សះផ្សាបាន និង ភាពមានៈរឹងរូស ដែលស្រដៀងគ្នានឹងការខ្វែងយោបល់គ្នា និង ភាពមានៈរឹងរូស ដែលមានរវាងចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. នោះ អ.ប.ជ. ដោយអលជ្ជី នឹងចូលរួមពាក់ព័ន្ធក្នុងប្រភេទនៃការរំលោភនីតិវិធី ដោយចេតនា ដោយឆន្ទៈ និង ដោយឥតស្រាក ដែលខ្លួនបានអះអាងថា ស.ច.ស. បានប្រព្រឹត្តដែរ។

## V. សន្និដ្ឋាន និង សំណូមពរ

៣៥. ចៅក្រមនៃ អ.ប.ជ. ត្រូវតែបញ្ចប់*ការភ័យខ្លាចលើការសម្រេច* ដែលកំពុងបន្តនេះ។ វៀរលែងតែពួកគាត់សម្រេចដោយឆាប់រហ័ស ដោយសំឡេងភាគច្រើនលើសលុប អំពីជំហានបន្ទាប់ ដែលត្រូវ

---

[99] *ផ្ទុយ* សំណើរបស់ ស.ព.អ. កថាខណ្ឌ ៣០។ ដីកាសម្រេចរួមលើផលប៉ះពាល់ ដោយសារស្ថានភាពថវិកា មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្ដី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៦។

[100] *រឿងក្ដី នួន ជា និងអ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៦) សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១២ ឯកសារ E138/1/10/1/5/7 កថាខណ្ឌ ៣៨ (ការគូសបញ្ជាក់បន្ថែម)។

[101] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ កថាខណ្ឌ ៦៥។

[102] *សូមមើល* សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៥ -១០៨។

អនុវត្តក្នុងរឿងក្ដី ០០៣ នោះពួកគាត់នឹងនៅតែបន្តរំលោភបំពានលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និង ធ្វើឱ្យអន្តរាយបន្ថែមទៀតដល់សុចរិតភាពនៃដំណើរការនីតិវិធី និង កេរដំណែលរបស់ អ.វ.ត.ក.។ ប្រសិនបើចៅក្រមនៃ អ.ប.ជ. គ្មានលទ្ធភាពទទួលបានសំឡេងភាគច្រើនលើសលុប ក្នុងការបញ្ជូនរឿងក្ដី ០០៣ ទៅជំនុំជម្រះទេ នោះពួកគាត់ *ត្រូវតែ* ប្រកាន់ខ្ជាប់តាមសម្បថតុលាការរបស់ខ្លួន និង គោរពដោយស្មោះត្រង់ទៅតាមច្បាប់ ដោយប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ក្នុងការបញ្ចប់រឿងក្ដី ០០៣ បោះត្រាសំណុំរឿង និង ដាក់បញ្ចូលវាទៅក្នុងបណ្ណសារ។ បើមិនដូច្នេះទេ គ្រាន់តែផ្ទេរផ្ដាស់កាតព្វកិច្ចទៅ អ.ជ.ត.ក. ឬ ស.ច.ស. ដើម្បីសម្រេចបញ្ចប់ដំណើរការនីតិវិធី និង បញ្ចប់អពលានុភាពផ្នែកស្ថាប័ន ដែលបានដាក់ដោយ អ.ប.ជ.។

អាស្រ័យហេតុនេះ អ.ប.ជ. គួរតែ ៖

ក. **ទទួលយក** សំណើរបស់ ស.ព.អ.

ខ. **បដិសេធ** សំណូមពររបស់ ស.ព.អ.

គ. **បញ្ចប់** សំណុំរឿង ០០៣

ឃ. **បោះត្រា** សំណុំរឿង ០០៣ និង

ង. **ដាក់បញ្ចូល** សំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ។

សូមលោកចៅក្រមទទួលយកសេចក្ដីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១២** ខែ**កក្កដា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្ដីលោក មាស មុត**

| | |
|---|---|
| អាង ឧត្ដម | Michael G. KARNAVAS |